**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧.០១៧.០១៨.០៧៧ ប្រ.ក.ព.ម

ថ្ងៃ ៧ង ១២កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៨

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលបានអនុញ្ញាតឲ្យទទួលប្រាក់បញ្ញើពីសាធារណជន

ធនាគារជាតិនៃកម្ពុជា សូមជម្រាបជូនសាធារណជន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ មេត្តាជ្រាបថា កន្លងមក ធនាគារជាតិនៃកម្ពុជា បានទទួលព័ត៌មានថា ជនមួយចំនួន និងគ្រឹះស្ថានឥណទានជនបទមួយចំនួនតូចដែលបានកម្លាយខ្លួនពីអង្គការមិនមែនរដ្ឋាភិបាល បាននិងកំពុងអូសទាញប្រជាពលរដ្ឋតាមរយៈការប្រមូលប្រាក់បញ្ញើពីសាធារណជនក្រោមរូបភាព "កិច្ចសន្យាខ្ចីប្រាក់" និងការផ្តល់អត្រាការប្រាក់ខ្ពស់ ព្រមទាំងការផ្តល់ប្រាក់កម្ចីល្មើសច្បាប់។

ធនាគារជាតិនៃកម្ពុជា សូមជម្រាបជូនថា គិតមកត្រឹមខែមីនា ឆ្នាំ២០១៨ ក្រៅពីគ្រឹះស្ថានធនាគារពាណិជ្ជ មានតែគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ៧ ប៉ុណ្ណោះ ដែលត្រូវបានអនុញ្ញាតឲ្យទទួលប្រាក់បញ្ញើពីសាធារណជន។ គ្រឹះស្ថានទាំងនោះគឺ៖

១. **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់** (PRASAC)
ទូរស័ព្ទ : (៨៥៥-២៣) ៩៩៩ ៩១១ គេហទំព័រ : http://www.prasac.com.kh

២. **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ វីសិនហ្វាន់ (ខេមបូឌា) អិលធីឌី** (VISIONFUND (CAMBODIA) LTD)
ទូរស័ព្ទ : (៨៥៥-២៣) ៩៦៩ ២៦៩ គេហទំព័រ : http://www.visionfund.com.kh

៣. **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត** (HATTHA KAKSEKAR LIMITED)
ទូរស័ព្ទ : (៨៥៥-២៣) ៩៩៤ ៣០៤ / ២២៤ ១០២ គេហទំព័រ : http://www.hkl.com.kh

៤. **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី** (AMK PLC.)
ទូរស័ព្ទ : (៨៥៥-២៣) ២២៤ ៧៦៣ គេហទំព័រ : http://www.amkcambodia.com

៥. **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រេឌីត ភីអិលស៊ី** (KREDIT PLC.)
ទូរស័ព្ទ : (៨៥៥-២៣) ២១៧ ៩៩២ / ៩៣០ ០០០ គេហទំព័រ : http://www.kredit.com.kh

៦. **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ខូអិលធីឌី** (AMRET Co., Ltd)
ទូរស័ព្ទ : (៨៥៥-២៣) ៨៨០ ៩៩២ / ៩៩១ ៣៩២ គេហទំព័រ : http://www.amret.com.kh

៧. **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី** (LOLC (CAMBODIA) PLC)
ទូរស័ព្ទ : (៨៥៥-២៣) ៩៩១ ៩៩១ គេហទំព័រ : http://www.lolc.com.kh

ក្រៅពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំង ៧ ខាងលើនេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានឥណទានជនបទដែលស្ថិតក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា មិនត្រូវបានអនុញ្ញាតឲ្យទទួលប្រាក់បញ្ញើពីសាធារណជនឡើយ ទោះជាក្រោមរូបភាពណាក៏ដោយ។

ចំពោះព័ត៌មានបន្ថែម សូមសាធារណជន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ទំនាក់ទំនងតាមប្រព័ន្ធទូរស័ព្ទ Hotline (០៩៨ ២២០ ០០២ / ០៨៥ ៦០០ ០០៣ / ០៩៧ ២៧៨ ៣០៣០ / ០៩៨ ២២០ ០០១) និងចូលមើលក្នុងគេហទំព័ររបស់ធនាគារជាតិនៃកម្ពុជា http://www.nbc.org.kh។

អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន និងស្នើសុំអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធមេត្តាសហការចូលរួមចាត់វិធានការតាមច្បាប់ជាធរមាន។

ទំនាក់ទំនង៖
អគ្គនាយកដ្ឋានត្រួតពិនិត្យ
ទូរស័ព្ទ៖ (៨៥៥) ៨៥ ៦០០ ០០២